ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

| ឯកសារបកប្រែ |
| --- |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 30-Aug-2016, 09:21 |
| CMS/CFO: Ly Bunloung |

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**Declassified to Public**
**12 June 2020**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# សំណើសុំសេចក្តីអធិប្បាយទាក់ទងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត សាងលីម
John R.WD. Jones

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេន្ទី
Suzana TOMANOVIC

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Beini YE

## I- ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ អោ អាន បានចូលបង្ហាញខ្លួនលើកដំបូងអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")[1]។ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ យើងបានជូនដំណឹង អោ អាន តាមរយៈសហមេធាវីរបស់គាត់ ថាមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ដែលថាគាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មបន្ថែម[2]។

2. នៅពេលសវនាការនាថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ យើងបានជូនដំណឹងទៅ អោ អាន តាមរយៈសហមេធាវីរបស់គាត់ ថាយើងបានកំពុងពិចារណាមិនស៊ើបសួរបន្ថែមអំពីអង្គហេតុជាក់លាក់ ដែលត្រូវបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី[3] ("IS") ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងទីតាំងឧក្រិដ្ឋកម្មនានា និងការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោមនៅតំបន់ ១[4] ("1SS") ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ[5] ("2SS") (ហៅរួមថា "ដីកាសន្និដ្ឋាន") និងចម្លើយតបទៅដីកាបញ្ជូនរឿងទៅពិនិត្យ D237[6] ("ចម្លើយតប") នៃការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") និងថាយើងអញ្ជើញភាគីធ្វើសារណាស្តីពីបញ្ហានេះ[7]។ អង្គហេតុទាំងនេះនឹងត្រូវបាន ហៅថាជាអង្គហេតុ ១ ដល់ ៨ ដូចខាងក្រោម។

## II. ពិភាក្សា

---

[1] សំណុំរឿង 00៤-D242, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង,* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥, ទំព័រ ៦-៧។

[2] សំណុំរឿង 00៤-D303, *កំណត់ហេតុនៃការបង្ហាញខ្លួនមកទៀត,* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ("ការបង្ហាញខ្លួនម្តងទៀត")។

[3] សំណុំរឿង 00៤-D1, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបី,* ថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ ("IS")។

[4] សំណុំរឿង 00៤-D65, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ១ និងការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោម,* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ("1SS")។

[5] សំណុំរឿង 00៤-191, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ,* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ("2SS")។

[6] សំណុំរឿង 00៤-D237, *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D237,* ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("ចម្លើយតប ក.សព")។

[7] ការបង្ហាញខ្លួនម្តងទៀត, ទំព័រ ៩។

3. ទាក់ទងអង្គហេតុខាងក្រោម[8] ដែលត្រូវបានចោទក្នុងដីកាសន្និដ្ឋាន និងចម្លើយតប យើងមានបំណង មិនបំពេញកិច្ចស៊ើបសួរបន្ថែម៖

- **អង្គហេតុ ១** - ការចោទប្រកាន់ទាំងអស់ទាក់ទងមន្ទីរសន្តិសុខ ទួលតាផ្លុង[9]។ បទចោទនានាដែលបានដាក់រួចហើយ គឺតំណាងគ្រប់គ្រាន់នូវវិសាលភាពនៃផ្នែកនេះនៃ IS។
- **អង្គហេតុ ២** - ការចោទប្រកាន់ទាំងអស់ទាក់ទងមន្ទីរសន្តិសុខវត្តកណ្ដាល[10]។ បទចោទនានាដែលបានដាក់រួចហើយ គឺតំណាងគ្រប់គ្រាន់នូវវិសាលភាពនៃផ្នែកនេះនៃ IS។
- **អង្គហេតុ ៣** - ការចាប់ខ្លួន និងការសម្លាប់ប្រជាជនចាមក្នុងភូមិភាគបូព៌ា[11]។ បទចោទនានាដែលបានដាក់រួចហើយ គឺតំណាងគ្រប់គ្រាន់នូវវិសាលភាពនៃផ្នែកនេះនៃ IS។
- **អង្គហេតុ ៤** - ការធ្វើទារុណកម្មនៅទួលបេង[12]។ មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់របស់ ក.ស.ព នេះ។
- **អង្គហេតុ ៥** - ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស[13]។ បើទោះបីជាមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់អំពីការសម្លាប់នៅទីតាំងនេះក៏ដោយ ក៏មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់របស់ ក.ស.ព ដែលថាទីតាំងនេះត្រូវបានប្រើប្រាស់ជាគុក។ គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ឲ្យជាក់លាក់ថាតើមនុស្សប្រភេទណាខ្លះដែលត្រូវបានកំណត់គោលដៅជាក់លាក់នៅទីតាំងនេះ។
- **អង្គហេតុ ៦** - ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនវៀតណាម និងចិននៅវត្តបារាយចានដែក[14]។

---

[8] គួរកត់សម្គាល់ថាបណ្ដុំនៃការចោទប្រកាន់កំពុងត្រូវបានលើកឡើងជាអង្គហេតុមួយ។

[9] IS, កថាខណ្ឌ ៥០-៥១។

[10] IS, កថាខណ្ឌ ៥២។

[11] IS, កថាខណ្ឌ ៤៥-៤៦។

[12] IS, កថាខណ្ឌ ៣០-៣៣, 2SS, កថាខណ្ឌ ១១, ចម្លើយតប ក.ស.ព, កថាខណ្ឌ ១-២។

[13] IS, កថាខណ្ឌ ៣០-៣១។

[14] IS, កថាខណ្ឌ ៥៣។

- **អង្គហេតុ ៧** - ការធ្វើទារុណកម្មនៅវត្តស្រង៉ែ[15]។ គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់របស់ ក.ស.ព អំពីការធ្វើទារុណកម្មនៅទីតាំងនេះ។
- **អង្គហេតុ ៨** - ការទទួលខុសត្រូវរបស់ អោ អាន ចំពោះសេណារីយ៉ូឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទក្នុង 1SS[16]- យើងពុំចាត់ទុកខ្លួនឯងថាបានទទួលពិចារណាដោយផ្ទាល់អំពីអង្គហេតុ ៨ ឬយើងមានផែនការពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរឡើយ ដោយហេតុផលមួយចំនួន៖ ការចោទប្រកាន់ក្នុង 1SS គឺកំហិតផ្នែកភូមិសាស្ត្រត្រឹមភូមិភាគពាយព្យ និងនិរតី។ ឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលត្រូវបានចោទដោយ ក.ស.ព ត្រូវបានរៀបរាប់ក្នុងកថាខណ្ឌ ៥ ដល់ ២០ នៃ 1SS។ ក្នុងការរៀបរាប់នេះ ពុំមានការលើកឡើងអំពីតួនាទីណាមួយដែលអាចជារបស់ អោ អាន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់។ អោ អាន ត្រូវបានលើកឡើងក្នុងកថាខណ្ឌ ២៣ តែមួយប៉ុណ្ណោះ ដែលគាត់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត *ក្នុងចំណោមប្រការផ្សេងៗ* នូវឧក្រិដ្ឋកម្មដែលត្រូវបានរៀបរាប់ក្នុង 1SS តាមរយៈការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម ដូចដែលបានរៀបរាប់ក្នុងកថាខណ្ឌ ២១[17] នៃ 1SS និងកថាខណ្ឌ ១៦ នៃ IS។ ត្រង់ប្រការនេះ យើងកត់សម្គាល់ឃើញថាកថាខណ្ឌ ១៦ នៃ IS ចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួម ដែលកំហិតផ្នែកភូមិសាស្ត្រត្រឹមភូមិភាគកណ្តាល៖ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅភូមិភាគពាយព្យ និងភូមិភាគនិរតី ពុំស្ថិតក្នុងវិសាលភាពរបស់វាឡើយ។ សម្រាប់កថាខណ្ឌ ២១ នៃ 1SS វាពិពណ៌នាអំពីសហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេស។ ប៉ុន្តែការចោទប្រកាន់អំពីសមាជិកភាពរបស់ អោ អាន នៃសហឧក្រិដ្ឋកម្មរួម មានលក្ខណៈទូទៅណាស់ ហើយការចោទប្រកាន់ដទៃទៀតដែលត្រូវបានធ្វើដោយ ក.ស.ព ក្នុងដីកាសន្និដ្ឋានទាំងនេះ ពុំផ្តល់ពន្លឺបន្ថែមស្តីពី សមាជិកភាពដែលត្រូវបានចោទប្រកាន់របស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមនៅទូ ទាំងប្រទេសនេះឡើយ។ គ្មានការចោទប្រកាន់អំពីបទល្មើសជាក់លាក់នូវអង្គហេតុ ទាក់ទង អោ អាន ឡើយ។ ពីទស្សនៈនៃយុទ្ធសាស្ត្រស៊ើបសួរ យើងពុំមានបំណងពង្រីក គោលដៅនៃកិច្ចស៊ើបសួរ ត្រឹមតែដោយសារ អោ អាន ត្រូវបាន

---

[15] IS, កថាខណ្ឌ ៤៩។

[16] 1IS, កថាខណ្ឌ ២៣។

[17] កថាខណ្ឌ ២៣ នៃ 1SS យោងទៅលើកថាខណ្ឌ ១៨ ពុំមែន ២១ ឡើយ ប៉ុន្តែយើងយល់ថាជាកំហុសកិច្ចការការិយាល័យ។

លើកឡើងក្នុង 1SS ក្នុងលក្ខណៈទូទៅឡើយ។ វិធីសាស្ត្រមួយទៀតនឹងញ៉ាំងឲ្យយើងស៊ើបសួរអំពី នួន ជា និងខៀវ សំផន ផងដែរ ពីព្រោះពួកគាត់ក៏ត្រូវបានលើកឡើងក្នុងលក្ខណៈនោះដែរ។ បើទោះបីជាត្រូវបានប្ដឹងអំពីការចោទប្រកាន់ប្រឆាំងចំណុចនេះក៏ដោយ ក៏យើងពុំពិចារណាឃើញថាវាជាការប្រើប្រាស់ប្រកបដោយប្រសិទ្ធផលនូវធនធានមានកំណត់របស់ ក.ស.ច.ស ដើម្បីពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរឲ្យហួសពីបទល្មើសទាំងប៉ុន្មានដែលត្រូវចោទប្រកាន់ដាក់លាក់ប្រឆាំងនឹងបុគ្គលទាំងនេះឡើយ។ ទោះជាក្នុង បរិបទនៃការជជែកដេញដោលអំពីយុត្តាធិការលើរូបបុគ្គលក៏ដោយ ក៏ អ.ជ.ត.ក បានទទួលស្គាល់ ការបែងចែកធនធានដែលមានកំណត់ថាជាការពិចារណាដ៏សមហេតុផលនៅពេលសម្រេចអំពីគោលការណ៍ស៊ើបសួរ[18]។ តាមទស្សនៈរបស់យើង ការពិចារណាស្រដៀងនេះត្រូវអនុវត្តនៅទីនេះ។

4. ដោយពិចារណាអំពីចំណុចខាងលើ នាពេលបច្ចុប្បន្នយើងមានបំណងដកចេញនូវអង្គហេតុ ១ ដល់ ៨ ពីកិច្ចស៊ើបសួរ។ លើសពីនេះទៀត យើងជឿជាក់ថាកិច្ចស៊ើបសួរបន្ថែម នឹងមិនកែប្រែស្ថានភាពនាពេលបច្ចុប្បន្ននេះឡើយ។

5. ជាសំណួរនៃផ្នែកច្បាប់ អង្គហេតុ ៤ ទៅ ៧ *តាមការសន្និដ្ឋានបឋម* ហាក់ដូចជាកម្មវត្ថុនៃការបដិសេធមួយផ្នែក បើទោះបីជាអង្គហេតុ ១ ដល់ ៣ សមស្របដើម្បីអនុវត្តវិធាន ៦៦ *ស្ទួន* នៃវិធានផ្ទៃក្នុងក៏ដោយ។ ប៉ុន្តែលទ្ធភាពនៃការអនុវត្តវិធាន៦៦*ស្ទួន*នៃវិធានផ្ទៃក្នុងទៅលើស្ថានភាពនានាដែលលក្ខខណ្ឌវិនិច្ឆ័យដទៃទៀតទាំងអស់នៃវិធាននោះកំពុងត្រូវបានបំពេញ មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ណាមួយ គឺពុំមានភាពច្បាស់លាស់។ ជាងនេះទៅទៀត វិធាននេះពុំទាន់ត្រូវបានអនុវត្តនៅឡើយមកទល់នឹងពេលនេះ ហើយហេតុដូច្នេះ គ្មានករណីយុត្តិសាស្ត្រដើម្បីផ្ដល់ពន្លឺស្ដីពីបញ្ហានេះឡើយ។ អាស្រ័យហេតុនេះ យើងសូមស្វាគមន៍ទស្សនៈរបស់ភាគីស្ដីពីការបកស្រាយវិធាន៦៦*ស្ទួន*នៃវិធានផ្ទៃក្នុងបរិបទនេះ។

6. សេចក្ដីសម្រេចនេះត្រូវ ដាក់ជាភាសាអង់គ្លេស យើងឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

---

[18] សំណុំរឿង ០០១-F28, *សាលដីកាលើសំណុំរឿង ០០១,* ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៧៩។

**តាមសម្អាងហេតុខាងលើ យើង៖**

7. **ជូនដំណឹង** ទៅភាគីថានាពេលបច្ចុប្បន្ន យើងមានបំណងដកចេញនូវអង្គហេតុ ១ ដល់ ៨ ពីកិច្ចស៊ើបសួរ។

8. **អញ្ជើញ** ភាគីដាក់សារណានានាដែលពួកគាត់អាចមានស្ដីពីចំណុចខាងលើ ពិសេសថាតើពួកគាត់យល់ឃើញថា ការបដិសេធ អនុលោមតាមវិធាន៦៧ នៃវិធានផ្ទៃក្នុង និង/ឬ ការអនុវត្តវិធាន៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង សមស្របដែរឬយ៉ាងណា ទាក់ទងអង្គហេតុ ១ ដល់ ៧ និង

9. **ជូនដំណឹង** ទៅភាគីថាសារណាតប ឬចម្លើយតប ទៅនឹងឯកសារដែលដាក់ដោយភាគីដទៃ ពុំត្រូវបានអនុញ្ញាតនៅពេលនេះឡើយ។

កាលបរិច្ឆេទ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ភ្នំពេញ

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**
**Co-juge d'instruction International**